*រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ១៩៩៤*

**អនុក្រឹត្យលេខ ៦៣ អ.នក្រ**

**ស្តីពីការប្រគល់ភារកិច្ច និង សិទ្ធិក្នុងការលក់**

**និង ធ្វើការនាំចេញផលិតផលកៅស៊ូជូនក្រសួង**

**កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

**រាជរដ្ឋាភិបាល**

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុវរ្ម័នព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញក្រឹត្យលេខ ១២ ក្រ ចុះថ្ងៃទី ១០ កុម្ភៈ ឆ្នាំ ១៩៩០ ប្រកាសអោយប្រើច្បាប់ ស្តីពីការកែប្រែការចាត់តាំងតួនាទី និង ភារកិច្ចរបស់អគ្គនាយកដ្ឋានចំការកៅស៊ូ

-បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃអគ្គនាយកដ្ឋានចំការកៅស៊ូ

-បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១៩ សីហា ឆ្នាំ១៩៩៣ ស្តីពីអគ្គនាយកដ្ឋានចំការកៅស៊ូត្រូវស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-យោងតាមស្មារតីនៃអង្គ ប្រជុំការងារក្រោម ព្រះរាជាធិបតីភាពនិងអធិបតីភាពសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ និង សម្តេចនាយករដ្ឋមន្ត្រីទី ២ កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៤ នៅទីរួមខេត្តកំពង់ចាម

**សំរេច**

**មាត្រា ១** : ប្រគល់ភារកិច្ច និង សិទ្ធិជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (អគ្គនាយកដ្ឋានចំការកៅស៊ូ) ក្នុងការចាត់ចែងលក់ សំរាប់បំរើផលិតកម្មឧស្សាហកម្ម-សិប្បកម្មក្នុងស្រុក និង ធ្វើការនាំចេញនូវផលិតផលកៅស៊ូ

គ្រប់ប្រភេទ លើកលែងតែជ័រកៅស៊ូបង្កក ដែលត្រូវសុំសេចក្តីសំរេចឯកភាពពីរាជរដ្ឋាភិបាល ព្រមទាំងធ្វើការនាំចូល នូវសំភារៈបរិក្ខារគ្រឿងបន្លាស់ និង មធ្យោបាយបំរើការងារផ្សេង ៗ បំរើអោយអាជីវកម្ម ផលិតកម្មកៅស៊ូ និង ការដាំដុះថ្មី ។

មាត្រា ២ : ក្រោយពីបានបំពេញកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ តាមច្បាប់កំណត់ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ( អគ្គនាយកដ្ឋានចំការកៅស៊ូ ) ត្រូវគ្រប់គ្រងចំណូលទាំងអស់ដែលបានមកពីការលក់ ផលិតផលកៅស៊ូគ្រប់ប្រភេទនេះសំរាប់ដោះស្រាយចំណាយក្នុងដំណើរការអាជីវកម្ម ផលិតកម្មកៅស៊ូ តាំងពីបៀវត្សរហូតដល់ទុនសំរាប់នាំចូលសំភារៈ បរិក្ខារគ្រឿងបន្លាស់ និង មធ្យោបាយ បំរើការងារផ្សេង ៗ តាមតម្រូវការចាំបាច់ ។ ឯទុនវិនិយោគ សំរាប់ការដាំដុះការថែទាំកូនកៅស៊ូ ពុំទាន់អោយផល និង ការសាងសង់ ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវលើកគំរោងច្បាស់លាស់ ស្នើសុំរាជរដ្ឋាភិបាលតាមគោល ការណ៍ ជាធរមាន ឬ អាចដោះស្រាយយកចំណូលមួយចំណែកបានមក ពីការលក់ផលិតផលកៅស៊ូ នេះយកមកប្រើប្រាស់ក្នុងករណី មានលទ្ធភាព ផ្ទុយទៅវិញក្នុងករណីប្រធានស័ក្តណាមួយសភាពការណ៍មិនអនុគ្រោះ នាំអោយបាត់តុល្យភាពរវាងចំណូល និង ចំណាយ ក្រសួងកសិកម្មរុក្ខា ប្រមាញ់ និង នេសាទ ត្រូវធ្វើរបាយការណ៍ លំអិតពីសភាពការណ៍ និង មូលហេតុជាក់ស្តែង រាយការណ៍ជូនរាជ រដ្ឋាភិបាល សុំជួយបំពេញបន្ថែមថវិកាមួយចំណែក ដើម្បីយកទៅដោះស្រាយការចាំបាច់មួយចំនួនក្នុងដំណើរការអាជីវកម្មផលិតកម្មកៅស៊ូដូចជាប្រាក់បៀវត្សជាដើម

មាត្រា ៣ : ក្នុងដំណើរការអនុវត្តន៍អាជីវកម្ម-ផលិតកម្ម ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ( អគ្គនាយកដ្ឋានចំការកៅស៊ូ) មានសិទ្ធិប្រើប្រាស់រូបិយប័ណ្ណដែលបានមកពីការលក់នាំចេញផលិតផល កៅស៊ូគ្រប់ប្រភេទនេះចំនួន ៣០% ដើម្បីនាំចូលអ្វីដែលជាតំរូវការក្នុងអាជីវកម្ម ផលិតកម្មកៅស៊ូ ។

ឯរូបិយប័ណ្ណនៅសល់ពីនេះត្រូវលក់ជូនរដ្ឋ តាមគោលការណ៍ច្បាប់ជាធរមាន ។

មាត្រា ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ នឹង អនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តតាមភារកិច្ចរៀងៗ ខ្លួននូវអនុក្រឹត្យ នេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *

*រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ១៩៩៤*

## អនុក្រឹត្យលេខ ១១៥ អ.នក្រ

## ស្តីពីការជូន មេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែមេសា ឆ្នាំ១៩៩៤